



# សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ



## និយមន័យ



មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការកំណត់ថា មានពិរុទ្ធភាព ឬគ្មានទោសនៅក្នុងការជំនុំជម្រះជាសាធារណៈលើកលែងតែក្នុងកាលៈទេសៈពិសេសមួយចំនួន។ ចំណុចនេះមានន័យថា ដំណើរការជំនុំជម្រះត្រូវតែធ្វើឡើងជាសាធារណៈ និងផ្ទាល់មាត់ស្របតាមគោលការណ៍ ដើម្បីធានានូវតម្លាភាពនៃដំណើរការកាត់ក្តី។

សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ត្រូវអនុវត្តនៅគ្រប់ដំណើរការជំនុំជម្រះរឿងព្រហ្មទណ្ឌទាំងអស់ ឬបញ្ហាពាក់ព័ន្ធនឹងបណ្តឹងផ្លូវច្បាប់។ ប៉ុន្តែ ចំណុចនេះមិនចាំបាច់ត្រូវតែអនុវត្តចំពោះគ្រប់ដំណើរការបណ្តឹងតវ៉ា ឬសេចក្តីសម្រេចមុនអង្គសេចក្តីដែលធ្វើឡើងដោយព្រះរាជអាជ្ញា និងអាជ្ញាធរសាធារណៈផ្សេងទៀតនោះទេ។ ដើម្បីឱ្យមានការគោរពសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ហើយការជំនុំជម្រះត្រូវតែធ្វើឡើងដោយ៖



បើកចំហសម្រាប់សាធារណជន ដោយក្នុងនោះរួមមានទាំងអ្នកសារព័ត៌មាន ហើយត្រូវធ្វើឡើងដោយផ្ទាល់មាត់។



សាធារណជនត្រូវតែទទួលបានការជូនដំណឹងអំពីទីកន្លែង និងកាលបរិច្ឆេទនៃការជំនុំជម្រះ។



ត្រូវផ្តល់មធ្យោបាយគ្រប់គ្រាន់ដើម្បីធានាថា អ្នកចូលរួមត្រូវមានចំនួនកំណត់មួយសមស្រប។

នៅក្នុងកាលៈទេសៈលើកលែងមួយចំនួនដែលសាធារណជន មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងដំណើរការជំនុំជម្រះ ការប្រកាសសេចក្តីសម្រេចដែលរួមមានទាំងលទ្ធផលរកឃើញសំខាន់ៗ ភស្តុតាង និងមូលហេតុស្របច្បាប់ត្រូវតែផ្សព្វផ្សាយ ជាសាធារណៈ។

## ក្របខ័ណ្ឌច្បាប់

### ច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ត្រូវបានការពារដោយមាត្រា ១៤ (១) "ជនគ្រប់រូបត្រូវ ទទួលបានការកាត់ក្តីដោយ "សមធម៌ និងជាសាធារណៈ" នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជាតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។



### ច្បាប់ជាតិ

ក្របខ័ណ្ឌច្បាប់ជាតិក៏ធានាសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ នៅមាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា "សវនាការដែលត្រូវធ្វើឡើងជាសាធារណៈ" និងមាត្រា ៧ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ "នៅគ្រប់ករណីទាំងអស់ តុលាការត្រូវប្រកាសសេចក្តីសម្រេចនៅក្នុងសាលសវនាការដែលបើកជាសាធារណៈ"។



# សារសំខាន់

សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈគឺជាមូលដ្ឋានគ្រឹះក្នុងការធានានូវតម្លាភាពនៃដំណើរការកាត់ក្តី និងគណនេយ្យភាពរបស់អ្នកដែលផ្តល់យុត្តិធម៌។ នេះគឺជាដំណើរការការពារប្រយោជន៍ដ៏សំខាន់សម្រាប់បុគ្គលម្នាក់ៗ ក៏ដូចជាសង្គមទាំងមូលតែម្តង។

សម្រាប់ភាគីដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងរួមទាំងជនជាប់ចោទផងនោះ ការពិនិត្យពិច័យជាសាធារណៈ អាចជួយត្រួតពិនិត្យប្រឆាំងនឹងការធ្វើសម្រេចចិត្តតាមអំពើចិត្ត ការរំលោភអំណាច និងការបំពាននីតិវិធី (រួមទាំងការប្រព្រឹត្តចំពោះភាគីនីមួយៗមិនស្មើគ្នាផងដែរ) ព្រមទាំងការជ្រៀតជ្រែក និងការជះឥទ្ធិពលពីភាគីខាងក្រៅផងដែរ។

ការរារាំងមិនឱ្យសាធារណជនតាមដានដំណើរការយុត្តិធម៌ គឺជាការគំរាមកំហែងលើគោលការណ៍នីតិរដ្ឋ។ ការបដិសេធសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ធ្វើឱ្យមានលំហសម្រាប់អំពើពុករលួយ និងនិទណ្ឌភាព និងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទដោយសារតែបញ្ហានេះធ្វើឱ្យពួកគេប្រឈមនឹងការផ្តន្ទាទោសមិនត្រឹមត្រូវ និងការសម្រេចទោសដោយអយុត្តិធម៌។

# ដែនកំណត់

ច្បាប់អនុញ្ញាតឱ្យមានការរឹតត្បិតទៅលើសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ នៅក្នុងលក្ខខណ្ឌជាក់លាក់ និងកាលៈទេសៈដែលបានកំណត់យ៉ាងរឹតត្បិតមួយចំនួន។ យោងតាមមាត្រា ១៤ (១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈអាចត្រូវបានរឹតត្បិត ប្រសិនបើមានការគំរាមកំហែងលើចំណុចដូចខាងក្រោម៖

- សីលធម៌ (ឧទាហរណ៍ ប្រសិនបើសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសផ្លូវភេទ)
- នៅក្នុងស្ថានភាពពិសេស នៅពេលតុលាការយល់ឃើញថា ការធ្វើជាសាធារណៈនឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌
- សន្តិសុខជាតិនៅក្នុងសង្គមប្រជាធិបតេយ្យ
- សណ្តាប់ធ្នាប់សាធារណៈ
- នៅពេលដែលផលប្រយោជន៍នៃជីវិតឯកជនរបស់ភាគីទាមទារដូច្នេះ (ឧទាហរណ៍ ការការពារអត្តសញ្ញាណជនរងគ្រោះនៃអំពើហិង្សាលើផ្លូវភេទ)

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights

Sweden Sverige

People Change the World Diakonia

CC BY NC SA